# សំណួរ-ចម្លើយអំពីវិធីសាស្ត្រនៃការទទួលខុសត្រូវសង្គម

**FAQs on the Social Accountability Approach**

## តើអ្វីទៅជាការទទួលខុសត្រូវសង្គម?

"ការទទួលខុសត្រូវសង្គម" សំដៅទៅលើសកម្មភាពជាក់លាក់ដែលធ្វើឡើងដោយក្រុមប្រជាពលរដ្ឋសាមញ្ញ ដើម្បីញ៉ាំងឱ្យមន្ត្រីសាធារណៈ អ្នកនយោបាយ និងអ្នកផ្តល់សេវា ទទួលខុសត្រូវចំពោះទង្វើនិងការអនុវត្តការងាររបស់ពួកគេក្នុងការផ្តល់សេវា ការលើកកម្ពស់សុខមាភាពប្រជាពលរដ្ឋ និងការការពារ សិទ្ធិរបស់ប្រជាពលរដ្ឋ ។

## តើអ្នកចង់មានន័យថា ចូលរួមក្នុងការបោះឆ្នោត ឬក៏ធ្វើការបះបោលនៅតាមផ្លូវ (អំណាចប្រជាជន)ឬ?

"ការបោះឆ្នោត" និង "អំណាចប្រជាជន" គឺជាសកម្មភាពរបស់ប្រជាពលរដ្ឋបែបប្រពៃណី។ ប៉ុន្តែវិធីសាស្ត្រនៃការទទួលខុសត្រូវសង្គម បង្ហាញនូវកំរិតផ្សេងៗគ្នា ហើយអ្នកខ្លះនិយាយថាជាការចូលរួមរបស់ប្រជាពលរដ្ឋកំរិតខ្ពស់។ មានការពាក់ពន្ធ័ពីប្រជាពលរដ្ឋ (ពិសេសប្រជាពលរដ្ឋក្រីក្រ):

- ពង្រឹងអំណាចពួកគេផ្ទាល់ដោយមានព័តិមានអំពីកម្មវិធីរបស់រដ្ឋាភិបាល ដូច្នេះពួកគេមានភស្តុតាងរឹងមាំ
- វិភាគព័តិមាននេះ
- ហើយធ្វើអន្តរាគមន៍ដោយផ្ទាល់ជាមួយមន្ត្រីសាធារណៈ អ្នកនយោបាយ និងអ្នកផ្តល់សេវា ចំពោះការទាមទារដែលពួកគេបម្រើផលប្រយោជន៍សាធារណៈប្រកបដោយ ប្រសិទ្ធិផល ប្រសិទ្ធិភាព និងយុត្តិធម៌។

## តើសកម្មភាពប្រភេទណាខ្លះដែលស្ថិតនៅក្នុងយុទ្ធវិធីការទទួលខុសត្រូវសង្គម?

សកម្មភាពទាំងនេះ រួមមាន : ការធ្វើគោលនយោបាយសាធារណៈដោយមានការចូលរួម ការធ្វើផែនការដោយមានការចូលរួម ការតាមដានមើលការចំណាយសាធារណៈ ការត្រួតពិនិត្យ និងវាយតម្លៃរបស់ ពលរដ្ឋចំពោះការបម្រើសេវារបស់រដ្ឋ (រៀបចំ បណ្ណរាយការណ៍)។

សកម្មភាពទាំងនោះរួមមាន កិច្ចប្រឹងប្រែងដើម្បីបង្កើនការយល់ដឹងរបស់ពលរដ្ឋ និងការប្រើប្រាស់យន្តការសាមញ្ញ នៃការទទួលខុសត្រូវសង្គម ( ឧ. តាមរយៈការអប់រំពលរដ្ឋ អំពីសិទ្ធស្របច្បាប់ និងសេវាកម្មដែលមាន) ឬកិច្ចប្រឹងប្រែងដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធិភាពនៃយន្តការទទួលខុសត្រូវសង្គម " **ផ្ទៃក្នុង** " ជាឧទាហរណ៍ : តាមរយៈការចូលរួមពាក់ពន្ធ័របស់ពលរដ្ឋនៅក្នុងគណៈកម្មការសាធារណៈ និងសវនាការក្រុមប្រឹក្សាពិគ្រោះ យោបល់ពលរដ្ឋ និងគណៈកម្មាធិការត្រួតពិនិត្យមើល ។

## តើនៅពេលណាដែលទស្សនាទានអំពីការទទួលខុសត្រូវសង្គមចាប់ផ្តើមកើត?

វាកើតមកពីទស្សនាទាននៃការចូលរួមរបស់ពលរដ្ឋនៅក្នុងអភិបាលកិច្ច។ នៅពេលដែលយន្តការរដ្ឋាភិបាល និង កម្លាំងទីផ្សារបរាជ័យក្នុងការលើកកម្ពស់នូវប្រយោជន៍សាធារណៈ ជាពិសេសក្នុងការលុបបំបាត់អំពើពុករលួយ និង កាត់បន្ថយភាពក្រីក្រ ចលនាចាប់ផ្តើមកើតឡើងដើម្បីឱ្យមានការចូលរួមដោយផ្ទាល់ពីពលរដ្ឋដែលជា ទិដ្ឋភាពជាក់ស្តែងនៃអភិបាលកិច្ច ។ អ្នកផ្តល់ជំនួយអន្តរជាតិដែលចង់ធានានូវការប្រើប្រាស់កម្ចី និងជំនួយឱ្យ បានត្រឹមត្រូវចំពោះរដ្ឋាភិបាលកំពុងអភិវឌ្ឍន៍ ក៏ផ្តល់យ៉ាងច្រើននៅក្នុងការគាំទ្រដល់ វិធីសាស្ត្រនៃការទទួលខុសត្រូវសង្គម ។

## តើមានអ្វីខ្លះធ្វើការងារជាមួយនឹងការទទួលខុសត្រូវសង្គម ៨000?

No. SA 8000 គឺជាប្រព័ន្ធស្តង់ដា និងជាប្រព័ន្ធពិនិត្យបញ្ជាក់ដើម្បីធានានូវកន្លែងធ្វើការងាររបស់មនុស្ស។ ជាស្ថាប័នមិនរកកម្រៃ ដែលមានឈ្មោះថា ការទទួលខុសត្រូវសង្គមអន្តរជាតិបង្កើតឡើងនៅឆ្នាំ ១៩៩៧។ ស្តង់ដា **SA8000** គឺជាស្តង់ដាដែលបញ្ជាក់នូវសវនកម្មដែលផ្អែកលើបទដ្ឋានការងារជាអន្តរជាតិ របស់អនុសញ្ញាអង្គការពលកម្មអន្តរជាតិ (ILO) សេចក្តីប្រកាសជាសកលអំពីសិទ្ធិមនុស្ស និងអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

## នៅពេលណាក្រុមពលរដ្ឋគួតែអនុវត្តការទទួលខុសត្រូវសង្គម?

ការទទួលខុសត្រូវសង្គមកើតឡើងនៅក្នុងវដ្តទាំងមូលនៃការគ្រប់គ្រងបែបប្រជាធិបតេយ្យ ។ ក្នុងន័យនេះគឺថា ពលរដ្ឋមិនគួរអនុវត្តនៅកំឡុងពេលការបោះឆ្នោត នៅពេលដែលពលរដ្ឋបោះឆ្នោត ។ វិធីសាស្ត្រនៃការទទួល ខុសត្រូវសង្គម អំពាវនាវឱ្យប្រជាពលរដ្ឋនៅតែឃ្លាំមើល និងប្រុងប្រយ័តយ៉ាងខ្ជាប់ខ្ជួនចំពោះការអនុវត្ត ការងាររបស់អ្នកដឹកនាំ ដែលជាប់ឆ្នោត អ្នកការិយាធិបតេយ្យ និងអ្នកផ្តល់សេវា។

## ដូច្នេះពលរដ្ឋគឺជាអ្នកដើតួសំខាន់បំផុតនៅទីនេះឬ?

មិនត្រឹមតែពលរដ្ឋទេ ប៉ុន្តែទាំងរដ្ឋាភិបាលផងដែរ ។ ពលរដ្ឋ និងរដ្ឋាភិបាលគឺជាអ្នកដើរតួយ៉ាងសំខាន់បំផុតក្នុងការទទួលខុសត្រូវសង្គម ។ រដ្ឋាភិបាលមានតួនាទីសម្របសម្រួលដើម្បីទទួលបាននូវគ្រប់ព័ត៌មាន ខណៈពេលដែលពលរដ្ឋត្រូវតែប្រើប្រាស់សិទ្ធិរបស់ គេដើម្បីចូលរួមនៅក្នុងអភិបាលកិច្ច ។ នេះមានន័យថាពលរដ្ឋត្រូវតែរៀបចំខ្លួនគេ ដើម្បីចូលរួមខ្ជាប់ខ្ជួននៅក្នុងការចូលរួមនេះប្រភេទនេះ ។

**តើភាពជាដៃគូរបស់រដ្ឋាភិបាល-ពលរដ្ឋដើតួយ៉ាងដូម្តេច?**

វិធីសាស្ត្រនៃការទទួលខុសត្រូវសង្គមសន្មតថា ទី ១ : រដ្ឋាភិបាលរក្សាទ្វាចំហរ ចំពោះការចូលរួមរបស់ប្រជាជន និងទី២ ពលរដ្ឋមានឆន្ទៈដើម្បីចូលរួមខ្ជាប់ខ្ជួននឹងរដ្ឋាភិបាល ។ ទំនាក់ទំនងដែលមានថាមពល គឺបង្កើតភាពជាដៃ គូរវាង ពលរដ្ឋ និងរដ្ឋាភិបាល ។ ក្រុមពលរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល មានឆន្ទៈដើម្បីពង្រីកសកម្មភាព ក្នុងការចូលរួមខ្ជាប់ខ្ជួន ឬធ្វើការងាររួមគ្នាជាមួយរដ្ឋាភិបាល ដើម្បីធានាថារដ្ឋាភិបាលធ្វើតាមភារកិច្ចរបស់គេ ក្នុងការផ្តល់សេវា លើកកម្ពស់សុខមាភាព និងការពារសិទ្ធិប្រជាជន ។

**តើភាពជាដៃគូអាចកើតឡើងទៅរួចដោយរបៀបណា?**

ភាពជាដៃគូនេះអាចកើតឡើងបានប្រសិនបើមានការជឿជាក់ទៅវិញទៅមក និងបើកចំហរ ។ កត្តាសំខាន់ប្រសិន បើមាន "ជើងឯក " ដែលជឿទុកចិត្ត និងគួឱ្យជឿបាន នៅក្នុងរដ្ឋាភិបាល ដែលគេអបអរចំពោះតម្លៃនៃការចូលរួម របស់ពលរដ្ឋ ។ ជើងឯកទាំងនេះគួតែបង្គ្រប់ដោយស្មើភាពនូវអង្គការពលរដ្ឋដែលគួរទុកចិត្តបានដែលអាចពិភាក្សា បាននៅក្នុងលក្ខណៈដែលមានសមត្ថភាព និងមានការរៀបចំ ។ ប្រសិទ្ធិភាពនៃភាពជាដៃគូពឹងផ្អែកយ៉ាងខ្លាំង លើសេរីភាពក្នុងការទទួលបានព័ត៌ ។ ព័ត៌មានបង្ហាញភស្តុងតាងក្នុងការសម្រេចចិត្ត និងសកម្មភាពនៃអ្នកទទួលខុស ត្រូវសង្គម ។ ក្រមសីលធម៌ ការទទួលខុសត្រូវ ប្រើដោយសមស្របចំពោះព័ត៌មានដែលអាចមាន ម្យ៉ាងទៀត ធ្វើឱ្យការងារការតស៊ូមតិការទទួលខុសត្រូវសង្គមគួជឿជាក់បាន ។

**តើនេះមានន័យថាក្រុមពលរដ្ឋគួតែយល់ស្របចំពោះរដ្ឋាភិបាលឬ?**

ជាការពិតមិនគួយល់ស្របទេ ។ ប្រើអហិង្សា ប៉ុន្តែការពារវិធីសាស្ត្រ ដូចជាប្រឆាំង រក្សានូវសកម្មភាពស្របច្បាប់ និងគួតែប្រើ ដោយយោងលើតម្រូវការស្ថានភាព ។

**ប៉ុន្តែមិនមានភាពប្រថុយប្រថានរបស់ក្រុមពលរដ្ឋ ដើម្បីសហការដោយរដ្ឋាភិបាលឬ?**

មិនមានទេ ប្រសិនបើអ្នកបង្កើតវិធានការជាក់លាក់ អំពីបរាជ័យ ឬក៏ជោគជ័យនៃការចូលរួម ដោយខ្លាប់ខ្លួន។ ការបរាជ័យដ៏ធំដើម្បីធ្វើតាមវិធានការទាំងនេះគួតែជាមូលដ្ឋានដើម្បីដកការគាំទ្រ នៅពេលដែលជោគជ័យគួតែ លើកទឹកចិត្តឱ្យមានការគាំទ្របន្ត ។ សាធារណៈជនគួតែដឹងអំពីការជោគជ័យ និងបរាជ័យនៃការចូលរួម ដោយខ្លាប់ខ្លួន។

## តើពលរដ្ឋសាមញ្ញអាចតស៊ូនឹងបញ្ហាធំក្នុងរដ្ឋាភិបាលតាមរយៈការទទួលខុសត្រូវសង្គមដោយរបៀបណា?

ពលរដ្ឋសាមញ្ញាគឺជាអ្នកផ្តល់ចំណែកយ៉ាងចំបងចំពោះការចម្រើនជឿនលឿននៃការទទួលខុសត្រូវសង្គម ប៉ុន្តែវា ជាការសំខាន់ គេត្រូវបញ្ចូលរួមគ្នា ហើយរួមបញ្ចូលសកម្មភាពរបស់គេដើម្បីឱ្យស៊ីនឹងបញ្ហាដែលធំ និងស្មុគស្មាញ។ តាមរយៈការភ្ជាប់ពលរដ្ឋ អំណាចរួមគ្នា និងការងារតស៊ូមតិដែលមានការរៀបចំ ទើបអាចធ្វើឱ្យគេមាន កម្លាំងខ្លាំងដើម្បីធ្វើការកែប្រែសង្គមបាន។

## តើវិធីសាស្រ្តនៃការទទួលខុសត្រូវសង្គម គួរធ្វើអោយស្របទៅនិងវប្បធម៌បន្ថែមទៀតដែរឬទេ?

ពិតប្រាកដណាស់ ការទទួលខុសត្រូវសង្គមទាទាមរអោយមានការផ្សារភ្ជាប់ទៅនិងវប្បធម៌។ វាត្រូវមានការស្វែងយល់ និងមានគម្រោង ដែលសមស្របទៅនិងគុណតម្លៃ ភាសារ និងការអនុវត្តរបស់ប្រជាជននៅតំបន់អាស៊ីប៉ូពាំ-ប៉ាស៊ីហ្វិក តែមួយ។ វាជាវិធីតែមួយគត់ដែលអាចធ្វើអោយ វិធីសាស្រ្តនៃការទទួលខុសត្រូវសង្គម មានការទទួលស្គាល់ មានអនុភាព និងត្រូវបានទទួលយក។